# ការសំភាសន៍របស់សេង ញឹប

កៈ អ្នកដែលសំភាសន៍គេ រ៉េន សារឿន ខៈ អ្នកដែលអោយគេសំភាសន៍សេង ញឹប

កៈ
ចឹងបងជាដំបូងខ្ញុំសុំថ្លែងអំណរគុណដល់បងដែលបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បងហាសហើយការសំភាសន៍នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យដែលនៅសហរដ្ឋអាមេរិចដែលមានឈ្មោះថាBYUដោយសារតែសកលវិទ្យាល័យមានបំណងចង់រក្សាប្រវត្តិរបស់ប្រជាជនខ្មែរទាំងអស់ទុកអោយកូនចៅជំនាន់ក្រោយបានស្គាល់ពីប្រវត្តិដូនតាចឹងហាសបងចាចឹងពេលដែលខ្ញុំសំភាសន៍បងនឹងខ្ញុំដាក់ការសំភាសន៍នឹងទៅក្នុងវេបសាយរបស់សកលវិទ្យាល័យដែរមានឈ្មោះថា www.cambodianoralhistories.byu.edu
ហាសបងចាចឹងតើបងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍របស់បងចូលទៅក្នុងវេបសាយដើម្បីពួកខ្ញុំអាចរក្សាទុកជូនបងទេបង

ខៈ ចាមិនអីទេព្រមតា

កៈ ចឹងសំរាប់ថ្ងៃខែដែរខ្ញុំបានសំភាសន៍បងគឺនៅថ្ងៃទី04 ខែឧសភា
ឆ្នាំ2017បងហើយការសំភាសន៍នេះគឺធ្វើនៅភូមិព្រៃទទឹង ឃុំបាយដំរាម ស្រុកបាណន់
ខេត្តបាត់ដំបង សំរាប់ខ្ញុំដែលសំភាសន៍បងខ្ញុំមានឈ្មោះថា រ៉េន សារឿន
ចាចឹងបងមានឈ្មោះអីដែលបងឈ្មោះពេញរបស់បងហាស?

ខៈ ខ្ញុំមានឈ្មោះថា សេង ញឹប

កៈ ចឹងបងមានឈ្មោះហៅក្រៅទេបង?

ខៈ អត់មានទេ

កៈ អត់មានសោះម៉ងហោសបង?

ខៈ អត់មានសោះ

កៈ ចឹងបងបងមានអាយុប៉ុន្មានឆ្នាំហើយឆ្នាំនេះ?

ខៈ ខ្ញុំមានអាយុ38ឆ្នាំហើយ

កៈ បងដឹងថាបងកើតនៅឆ្នាំអីទេ?

ខ៖  កើតនៅឆ្នាំ1979

ក៖ កើតនៅឆ្នាំ1979ណាបង តើកើតនៅថ្ងៃទីប៉ុន្មានបង?

ខ៖ បើមិនដឹងដឹងតែថ្ងៃច័ន្ទបើមិនដឹងថ្ងៃទីប៉ុន្មាន

ក៖ បងអត់ដឹងកើតនៅថ្ងៃទីប៉ុន្មានខែប៉ុន្មានទេ?

ខ៖ អត់ដឹង

ក៖ ចុះឆ្នាំខ្មែរហោសបង?

ខ៖ ឆ្នាំខ្មែរក៏អត់ដឹងដែរបើម៉ែហោសអត់ដឹងដែរនឹង

ក៖ ចឹងអ៊ុំអត់ដឹងដែរណាអ៊ុំបើដឹងតែខ្លួនឯងកើតថ្ងៃច័ន្ទ

ក៖  ចុះអាឆ្នាំចរ ឆ្នាំកោ ឆ្នាំជូត ឆ្នាំឆ្លូវអីបងអត់ដឹងទេណា?

ខ៖  អរឆ្នាំនឹងហោសខ្ញុំឆ្នាំមមែ

ក៖ បងឆ្នាំមមែចុះស្រុកកំណើតបងកើតបងកើតនៅណាដែរ?

ខ៖  កើតនៅភូមិស្តៅ ភូមិស្តៅយើងអីណាណាភូមិស្តៅ ស្រុកស្តៅយើង

ក៖ ស្រុកស្តៅនៅជិតប៉ៃលិននឹងមែន

ខ៖ ជិតប៉ៃលិននឹងហើយ

ក៖ បងដឹងថាឃុំអីអត់?

ខ៖
អត់ដឹងទេកើតមកតាំងពីតូចនឹងមកគាត់យកចេញមកនឹងបណ្តោយនឹងបើមិនដឹងថាស្រុកស្អីៗមិនដឹងទេបើកើតនៅនឹងម៉ែឪប្រាប់ថាកើតនៅនឹង

ក៖  ចុះបងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរបង?

ខ៖  បងប្អូនចំនួន6នាក់

ក៖   បងប្អូនចំនួន6នាក់ទាំងអស់ ហើយបងជាកូនទីប៉ុន្មានដែរបង?

ខ៖ ខ្ញុំជាកូនទី1

ក៖ ចឹងបងជាបងគេចុះប្អូនៗរបស់បងគាត់មានឈ្មោះអីគេខ្លះដែលបង?

ខ៖ ប្អូនខ្ញុំឈ្មោះអឿន ឈ្មោះនាង ឈ្មោះណាក់ ក្មេងប្រុសឈ្មោះវី ឈ្មោះពៅ ចាទាំងអស់6នាក់

ក៖ 6នាក់ចាចុះបងមានចាំសាច់រឿងទេអនុស្សាវរីយ៍ជាមួយពួកគាត់ជាមួយបងប្អូនបងហាស?

ខ៖ ហ៊ាមានតាកំសត់កំរណាស់បងប្អូនខ្ញុំមានតែមុនដំបូងបងទី1មានតែធ្វើខ្ញុំគេចិញ្ចឹមម៉ែឪតាំងពីតូចតាំងពីក្មេងតាំងពីអាយុ10ទៅរែកខ្សាច់ប្រវត្តិរឿងរែកខ្សាច់ហាសចេញពីពីដើមនឹងម្តាយយកបងពីស្រុកស្តៅនឹងមកតាំងពីតូចមកទៅនៅកំពង់ឆ្នាំម្តាយហាសយកទៅនៅកំពង់ឆ្នាំតែដល់ពេលអាយុដល់9-10ឆ្នាំបានមកនៅខេត្តបាត់ដំបងយើងនឹងនេះ មកនៅស្រុកបាណន់យើងនឹងនេះនៅបទសំរាយើងបាយដំរាមហោសដល់ពេលនឹងទៅដឹងក្តីពេញក្តីចេះរកស៊ីចិញ្ចឹមម្តាយបេះម្ទេះ ចេះធ្វើជំរះស្មៅម្ទេះគេដើរស៊ីឈ្នួលអោយគេមានប្រវត្តិគេច្រើនហាសហើយចេះរែកខ្សាច់រែកអីដើម្បីមកចិញ្ចឹមម្តាយចិញ្ចឹមបងប្អូន5-6នាក់មានតែបងទេដែលជាបងគេបង្អស់ ដល់ហើយបន្ទាប់មកអាប្អូនដល់អាប្អូននឹងគ្នាចេះអាយុរៀងច្រើនទៅបងអាយុ15ឆ្នាំអីទៅប្អូនអាយុ12ឆ្នាំទៅ13ឆ្នាំអីទៅបានជួយធ្វើការជំនួសដៃជំនួសជើងទៅណាស់បានរកលុយបានទៅបានទិញអង្ករនឹងបានទិញអីហូបទៅប្រវត្តិមានតែបងប្អូន2នាក់ទេដែលកំសត់កំរតាំងពីក្មេងមកចេះចិញ្ចឹមម្តាយចេះចិញ្ចឹមអីហោសហើយដល់ពេលដល់បន្ទាប់មកដល់អាឡូវរហូតដល់បងមានប្តីមានស្អីៗទៅបានបែកពីម៉ែទៅបានប្អូនៗនឹងជួយចិញ្ចឹមម្តាយទៅបានធ្វើផ្ទះបានធ្វើអីនៅនឹងគេបានរុំរស់បាននៅសព្វថ្ងៃចឹងទៅណាស់

ក៖ ចុះបងកាលនៅពីតូចហាសបងចូលចិត្តលេងអីគេខ្លះជាមួយបងប្អូនរបស់បងហាស?

ខ៖ ពីតូចហោសពីតូចមកចូលចិត្តលេងបាយឡឹកបាយឡលេងជាមួយបងប្អូននឹងទៅមិនដែលលេងជាមួយញាតិដ៏ទៃអីទេ តែបងប្អូនអែងនឹងជូនទៅវៃគ្នាទៅជូនទៅទះគ្នាទៅវាអាសារមានរឿងជាមួយគ្នាហាសអា

សាមានរឿងជាមួយគ្នាខាងបាយឡឹកបាយឡូរនឹងទៅ
សប្បាយផងទៅវៃផងទៅទះគ្នាតែបងប្អូននឹង

ក៖  ហើយចុះបងដូចជាបងនៅសព្វថ្ងៃហាសដូចជាបងប្អូនបងនៅណាខ្លះដែរ
ហើយគាត់ធ្វើការនៅណាខ្លះដែរបង?

ខ៖
បងប្អូនមើលគេបែកអស់ហើយគេមានប្ដីមានប្រពន្ធបែកអស់ហើយហើយនៅតែលីវ3នាក់អស់2នាក់នៅលីវតែ2នាក់ទេនៅលីវតែ2នាក់កវៅពីនឹងគេមានប្ដីមានប្រពន្ធ4នាក់ហើយដល់ពេលចឹងទៅគេរកស៊ីដោយខ្លួនគេចឹងទៅបើមីប្អូននោះមួយបន្ទាប់វាបន្ទាប់ទី3ហាសវារៀងកំសត់ក្រជាងគេគ្នាពិបាកជាងគេនឹងអែងសព្វថ្ងៃហោសកូន2នាក់ហើយវាលំបាកជាងគេដើររកស៊ីទៅដកដំឡូងទៅអីទៅជីវភាពតែប៉ុណ្ណឹងអែង

ក៖ ចុះម្ដាយរបស់បងគាត់ឈ្មោះអីគេដែរបង?

ខ៖  ម្ដាយខ្ញុំឈ្មោះ អឹម ស៊ុម

ក៖ ចុះឪពុកហោសបង?

ខ៖  ឪពុកឈ្មោះ សេង កុសល

ក៖ បងមានដឹងថាពួកគាត់ហាសអ៊ុំប្រុសអ៊ុំស្រីមានដឹងថាគាត់កើតនៅឆ្នាំណាទេបង?

ខ៖ អត់ដឹងដែរគាត់ប្រាប់ក៏គាត់ភ្លេចដែរមិនដឹងថាគាត់កើតនៅឆ្នាំណាអីឆ្នាំណីទេអត់សូវចាំ

ក៖ ចុះគាត់អាយុប៉ុន្មានដែរបង?

ខ៖  លោកឪអាយុ78-79ឆ្នាំនេះហើយ

ក៖  ចុះម្ដាយវិញ?

ខ៖  ម្ដាយអាយុ67ឆ្នាំ

ក៖  ចឹងគាត់បងគ្នា10ឆ្នាំណាបង

ខ៖  នឹងហើយគាត់បងគ្នា10ឆ្នាំគាត់បងប្ដីប្រពន្ធគ្នា10ឆ្នាំ

ក៖  ហើយចុះបងដឹងថាពួកគាត់កើតនៅណាអត់?

ខ៖

អត់ដឹងអត់ដែរបានដេញដោលសួរគាត់ផងអត់ដឹងថាប្រវត្តិគាត់កើតនៅណាទោះគាត់ប្រាប់ក៏ភ្លេចដែរមិនដែរសួរដេញដោលអារឿងប្រវត្តិគាត់លែងតែខ្វល់អារឿងអត់ស៊ីច្រើនជាងក្នុងគ្រួសារហាសណា

ក៖

ចុះបងដូចជាកាលបងនៅតូចៗហាសបងមានដឹងថាឪពុកម្តាយរបស់បងធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែល?

ខ៖

គាត់មើលតាំងពីដឹងថាតូចគាត់ពិបាកគាត់លំបាកលំបិណយ៉ាងម៉េចគាត់លីសែងកាលគាត់នៅកំពង់ឆ្នាំហាសគាត់លីសែងទៅឃើញត្រីធំៗហាសគាត់លីទាំងខេងៗលីម្តងៗ1ខេងគ្នា3-4នាក់ចឹងទៅទៅរត់ល្មកចឹងទៅដើម្បីចិញ្ចឹមកូនចិញ្ចឹមប្រពន្ធនឹងស្គាល់ប្រវត្តិគាត់គាត់ដើរស៊ីឈ្នួលគេចឹងទៅគាត់ទៅរែកខ្សាច់រែកអីចឹងទៅបេះបន្លែបេះបន្លកយកទៅលក់អោយគេចឹងទៅធ្វើម៉េចដើម្បីដោះដូរទិញអង្ករទិញអីហូបដើម្បីដោះដូរមកជីវភាពនៅក្នុងក្រុមគ្រួសារ

ពិបាកណាស់រឿងថាក្នុងក្រុមគ្រួសាររបស់បងពិបាកណាស់បើនិយាយពីរឿងប្រវត្តិទៅវាលំបាកច្រើនណាស់ទំរាំបានដល់សព្វថ្ងៃនឹងវាគ្រាន់រាងធូធារចន្តិចទោះកូនទៅវារកបន្តិចទៅចិញ្ចឹមម្តាយខ្លះអីខ្លះវាអោយមានវាមិនមានទេវាបានគ្រាន់តែថាវាបានមើលទប់ទល់ហូបៗបានឆ្អែតៗអរគុណហើយបានឆ្អែត

ក៖ ចុះឪពុកម្តាយរបស់បងយ៉ាងម៉េចដែរបងកាចរឺមួយក៏ស្លូត?

ខ៖

ស្លូតណាស់ស្លូតមិនចេះរករឿងកូនចៅទេកូនចៅចង់ធ្វើអីក៏ធ្វើទៅអោយតែកូនរកបានកុំអោយតែកូនដើរឆក់ដើរប្លន់គេគាត់ប្រដៅចឹងកុំអោយកូនដើររកស៊ីលួចគេបើកូនរកស៊ីដើរធ្វើកម្មករគេរឺក៏រកស៊ីធម្មតាគាត់ប្រដៅចឹងបើបង្គាប់អោយដើររកស៊ីលួចគេលួចអីគាត់មិនអោយធ្វើអញ្ចឹងទេគាត់កាចអាកន្លែងនឹងតិចហើយ

ក៖

ចុះបងសាច់រឿងណ្វកគាត់បងមានចាំសាច់រឿងពួកគាត់ទេអនុស្សាវរីយ៍ចឹងហាសណាស់?

ខ៖

រឿងអនុស្សាវរីយ៍នឹងគាត់បងនឹងគាត់នឹងតាមនិយាយទៅតាំងពីបងបានប្ដីមកចិញ្ចឹមកូនទាំង4នាក់ប្ដីគេយកប្រពន្ធទៀតទៅហើយក៏លែងលះគ្នាទៅហើយក៏ចិញ្ចឹមកូនទាំង4នាក់ហើយដល់ពេលនឹងទៅម៉ែឪនឹងអែងជួយចិញ្ចឹមកូនចិញ្ចឹមចៅអីទៅបងប្អូននឹងជួយមើលជួយអីទៅកើតកូនភ្លោះនេះអែងភ្លោះទាំងពីរនឹងនេះភ្លោះទាំងពីរនឹងវេទនាណាបានអង្គការគេជួយផងម៉ែឪគាត់ជួយជ្រោងផងជួយចិញ្ចឹមជួយអីនឹងប្រវត្តិសុំទឹកដោះគោខាងអង្គការគេជួយហាសជួយបានអោយរំរស់រហូតទាល់តែបានសព្វថ្ងៃនឹងហើយគាត់កាលណុងយើងអត់កាលកើតកំណើតវានឹងជំនាន់នឹងវាអត់ពេលនឹងវាអត់ដល់ពេលកើតវាមកកូនភ្លោះចឹងទៅបានបងប្អូននឹងអែងបានជួយចិញ្ចឹមជួយអីទៅខ្ញុំដើររកស៊ីទៅស្រុកគេនៅក្រៅចឹងទៅបានធូធារបន្តិចមកក៏ចិញ្ចឹមកូន4នាក់ទៀតទៅរហូតដល់កូនធំ

ក៖

ចុះម្ដាយឪពុករបស់បងគាត់មានធ្លាប់និយាយរឿងប្រវត្តិពួកគាត់កាលនៅក្មេងៗប្រាប់បងពីប្រវត្តិជូរចត់អីគេខ្លះទៅបង?

ខ៖

ធ្លាប់លឺគាត់ប្រាប់ដែលថាពីជំនាន់គាត់នឹងវេទនាណាអត់បាយអត់ទឹកគេរកបាញ់ចោលគេរកសំលាប់គាត់ព្រោះគាត់តស៊ូនឹងធ្វើទាហ៊ានហាសឪពុកធ្វើទាហ៊ានដល់ពេលនឹងទៅគេរកគាត់គេរកបាញ់គាត់ចោលទៅធ្វើទាហ៊ានតស៊ូចេះតែរត់គេចៗទៅរហូតមករស់នៅដល់សព្វថ្ងៃនឹងទៅហើយគាត់ថាជួនកាលអត់បាយអត់ទឹកប្រាំពីរយប់ប្រាំពីរថ្ងៃហោសដោយសារទៅសមរភូមិគាត់ទៅឈ្បាំងនឹងគេទៅអត់បាយអត់ទឹកទៅចឹងអែងមានតែប៉ុណ្ណឹងគាត់និយាយរឿងប្រវត្តិចឹងអែងបើរឿងបងគាត់មិនដែលនិយាយប្រាប់ទេគាត់និយាយចឹងគាត់និយាយតែប្រវត្តិគាត់ធ្វើទាហ៊ានមកតស៊ូមកយូរហាសតាំងពីរសម័យថាលុនណុលម៉េសនៅសម័យលុនណុលគាត់គាត់និយាយតាំងពីសម័យលុនណុលនឹងថាបិះងាប់បិះរស់ហើយតស៊ូប្រវត្តិគាត់លឺគាត់និយាយចឹងហាសបើកុហកក៏កុហកតាមគាត់ដែលពៅថាកុហកក៏ថាបានថាមិនជឿគាត់ក៏ថាបានព្រោះថានៅសម័យគាត់ម៉ាសារីគាត់នៅសល់តែគាត់នឹងអែងនឹងហើយសល់តែគាត់នឹងគាត់ចេះតស៊ូរហូតមកដល់សព្វថ្ងៃ

ក៖  ចុះបងមានចាំឈ្មោះជីដូនជីតារបស់បងទេខាងម្ដាយហាសបង?

ខ៖
ខាងម្តាយស្គាល់យាយអត់ស្គាល់តាទេព្រោះកើតអត់ទាន់ទេបើយាយស្គាល់គាត់ឈ្មោះយាយសឿន

ក៖ ចុះតាបងស្គាល់ឈ្មោះអីទេ?

ខ៖ ថាតាអត់ស្គាល់ទេ

ក៖ ចុះខាងឪពុកហោសបង?

ខ៖ ខាងឪពុកស្គាល់យាយ អត់ស្គាល់តាទេ

ក៖ ស្គាល់តែយាយដែរអត់ស្គាល់តាចុះយាយឈ្មោះអីគេបង?

ខ៖
គាត់ឈ្មោះយាយអីទេនេះអើរយាយម៉ែខាងឪពុកហាសឈ្មោះយាយថូនស្គាល់តែខាងយាយនឹងអែងខាងឪពុក

ក៖
ចុះអ៊ុំមានប្រាប់ប្រវត្តិពីលោកយាយថាម៉េចអីម៉េចមកកាន់បងទេថាពួកគាត់មានជីវិតតស៊ូម៉េចខ្លះអីខ្លហាម៉េចចឹងហាសណាស់?

ខ៖
អត់ដែរលឺគាត់និយាយអីផងព្រោះយាយនឹងលឺថាទើបតែប្តីគាត់ធ្វើបាប់ណាស់បានតែឪពុកនឹងឪពុកបងចិញ្ចឹមគាត់ទៅណាស់ចិញ្ចឹមបងប្អូនរហូតលឺគាត់និយាយនឹងហើយចិញ្ចឹមបងប្អូនរហូតដល់គាត់មានប្រពន្ធហើយពេលមានប្រពន្ធហើយនៅតែចិញ្ចឹមរហូតហើយចិញ្ចឹមម្តាយទៀតព្រោះម្តាយនឹងមេម៉ាយចិញ្ចឹមកូនចិញ្ចឹមប្អូនរហូតនឹងហើយគាត់នឹងបងគេដល់ហើយមាននរណាចិញ្ចឹមមានតែគាត់នឹងជាអ្នកចិញ្ចឹមនឹងអែងបងប្អូនទៅ

ក៖ ចុះក្រុមគ្រួសាររបស់បងរស់នៅខែនេះយូរនៅបង?

ខ៖ នៅឡើងជាង30ឆ្នាំហើយ

ក៖ រស់នៅជាង30ឆ្នាំ

ខ៖
ព្រោះមើលនៅនេះមើលកាលមកថាអាយុជាង10ឆ្នាំចុះអាឡូវអាយុឡើង37ឆ្នាំហើយវាមិនដល់30ឆ្នាំទេវាខ្វង់20ឆ្នាំជាងផ្លាយអីនឹង20ឆ្នាំផ្លាយហើយតាំងពីនៅក្មេង

ក៖ ចុះបងមានបងប្អូនណាដែលគាត់បានរស់នៅក្រៅពីប្រទេសខ្មែរទេបង?

ខ៖ អត់មានផងអត់មានសោះ

ក៖ ចុះស្វាមីរបស់បងគាត់ឈ្មោះអីដែលបង?

ខ៖ ស្វាមីឪអានេះហៃសឈ្មោះក្រា

ក៖ បងមានចាំថាបងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅឆ្នាំណាដែរបង?

ខ៖ នៅឆ្នាំ1994គឺឆ្នាំ1994

ក៖ ឆ្នាំ1994?

ខ៖ ឆ្នាំ1994យើងនេះយូរហើយវា20ផ្លាយឆ្នាំជាងហើយវា23-24ឆ្នាំហើយ

ក៖ បងរៀបកាពោយចិត្តអែងរឺឪពុកម្តាយជាអ្នកផ្សំផ្គុំអោយបង?

ខ៖ ម៉ែឪជាអ្នកផ្សំផ្គុំអោយ

ក៖ ចាមានថ្លៃជំនូនទេ?

ខ៖ មានម៉ែជំនូនកាលនឹងម៉ានដែលម៉ែ?មានមាស1ជី

ក៖ មាស1ជីកាលណុងថ្លៃហាសណាបង

ខ៖ ថ្លៃកាលណុងមាស1ជីយកមាន់ យកទា
យកជ្រូកកាលធ្វើនឹងដូចជា15តុវាភ្លេចដែរនឹងហាសវាយូរហើយនឹង

ក៖
ចុះអាចប្រាប់ពីស្វាមីបងថាបានជួបនៅណាដែរហើយជួបពេលណាហេតុអ្វីបានជាស្រលាញ់គ្នាចឹងាហាសណាស់បង?

ខ៖ អរជួបនៅបទសាលាយើងនឹង

កៈ ជួបនៅនោះវិញណោះបង?

ខៈ ជួបនៅណោះតែពេលបានមករៀបអាពាហ៍ពិពាហ៍មករៀបនៅព្រៃទទឹងយើងនេះ

កៈ ហើយបងចេះអាននឹងចេះសរសេរអក្សរខ្មែរបានល្អប៉ុន្មានដែរបង?

ខៈ អរខ្ញុំអត់ចេះទេ

កៈ អត់បានរៀនទេណ

ខៈ
អត់បានរៀនទេកាលណុងហរត់ផងចេះទាន់អាគេរត់មិនសូវថាចង់រៀនសាលាកាលម្ហឹកនឹងហាសគិតតែការងារព្រោះតែគិតថាជីវភាពយើងវាអត់ពេកហាសគិតតែរកការងារធ្វើសំរាប់ចិញ្ចឹមម៉ែចិញ្ចឹមឪហើយចិញ្ចឹមបងចិញ្ចឹមប្អូនអីចឹងហាសហើយមានណាធំមានតែបងនឹងហើយធំជាងគេ

កៈ ចុះបងមានចេះនិយាយភាសាអីផ្សេងក្រៅពីភាសាខ្មែរទេបងដូចជាភាសាថៃ ភាសាចិន ភាសាជប៉ុនអីទេបង?

ខៈ អត់ចេះទេអត់ចេះ

កៈ ចុះបងមានមិត្តភក្តិស្និទ្ធិស្នាលទេ?

ខៈ អត់ទេអត់ដែលមានទេអត់មានទេ

កៈ ចុះបងធ្លាប់ធ្វើស្រែទេ?

ខៈ អរអត់

កៈ ចុះធ្វើចំការអត់មានដែល?

ខៈ ធ្វើចំការអីអត់មានសោះ

កៈ ចុះបងមានធ្លាប់ធ្វើមិខរបរអាជីវកម្មបែបលក្ខណៈគ្រួសារអីទេបង ដូចជាចិញ្ចឹមមាន់ ចិញ្ចឹមទារីប្រកបមិខរបរលក់ដូរអីទេបង?

ខ៖ មានចិញ្ចឹមទាមាន់មិនសូវបានចិញ្ចឹមទេព្រោះលែងតែដើររកស៊ីសំណង់មាន
ធ្វើការសំណង់ធ្វើខ្ញុំគេចឹងទៅណាស់ដើរមករស់ធ្វើជីវភាពមួយពេល
ទៅពីរពេលយើងដើររកទៅមួយខែ20-30ម៉ឺនពេលខ្លះ20ម៉ឺន

ក៖  ចុះនៅក្នុងជីវិតរបស់បងបងធ្លាប់ធ្វើការអីគេខ្លះដែរបង?

ខ៖
គ្មានបានថាធ្វើការក្នុងផ្ទះនៅឆ្នាំជាមួយគេធ្វើការឆ្នាំហាសទៅធ្វើការជាមួយគេទៅ2ឆ្នាំទៅមកផ្ទះមកផ្ទះម្តងទៅធ្វើការឆ្នាំ

ក៖  ចឹង2ឆ្នាំមកផ្ទះម្តងណោះបង
ហើយបងតាំងពីក្មេងរហូតមកដល់អាឡូវហាសបងតើជីវិតរបស់បងមានការផ្លាស់ប្តូរអីខ្លះបង?

ខ៖
សព្វថ្ងៃផ្លាស់ប្តូរព្រោះបងនៅជាមួយគេទៅដូចថាគេអាណិតស្រណោះបងអីចឹងទៅយើងរកលុយបានចឹងទៅគេណិតស្រណោះគេជួយអោយយើងខ្លះទៅគេបានជីវភាពធូធារតាក់តិចហើយមិនដូចលើកមុនទេ
បើថាយើងដូចលើកមុនអានឹងបានវេទនាមេនទែនសព្វថ្ងៃធូធារទៅដល់ពេលកូនធំទៅបានជួយខ្លះអីខ្លះទៅមិនអោយម្តាយពិបាក

ក៖  ចុះបងចូលចិត្តពិសារម្ហូបអីគេខ្លះដែរបង?

ខ៖ ហាខ្ញុំហោស
អើរ……នៅស្រុកខ្មែរយើងនឹងមានស្អីទេស្ងោរស្ពំបុកអំបិលម្ទេសសាច់ជ្រូកសាច់អីតែប៉ុណ្ណឹងអែង សាច់មាន់យើងនឹងអែង

ក៖
ចាហើយបងចូលចិត្តលេងល្បែងកំសាន្តប្រជាប្រិយអីគេខ្លះដែរបងដូចជាល្បែងចោលឈូងលេងបោះអង្គុញ ទាញព្រាត់ លេងអីផ្សេងៗហាសបង?

ខ៖ ខ្ញុំហោសខ្ញុំចូលចិត្តលេងបោះឈូង រាំរបាំ
រាំអីចង់ចំណូលអីជាការសប្បាយនឹងគេទៅរាំរបាំដូចថាស្រីខ្មែរយើងហាសស្រីខ្មែរយើងមានអីសប្បាយជាងគេមានតែរាំរបាំនឹងអែងហើយមានបោះឈូង

បោះអង្គុញទាញព្រាត់យើងដូចអញ្ចឹងអែងខ្មែរយើងមានអីមានតែអញ្ចឹងអែងជាការសប្បាយ

កៈ
ហើយបងមានចងចាំបទចំរៀងកាលពីមុនណាដែរបងបានច្រៀងរឺមួយរៀនច្រៀងអត់បង?

ខៈ អឺ.....អត់ចេះច្រៀងសោះ

កៈ អត់សោះម៉ងហោសបង?

ខៈ អឺ......មិនដែរចេះច្រៀងទេ

កៈ ចុះបងប្អូនលបងរឺក៏បងមានចេះលេងឧបករណ៍ដន្ត្រីអីទេ?

ខៈ អត់អត់ៗៗអត់សោះម៉ង់

កៈ
ចុះបងផ្ទះរបស់បងមានលក្ខណះម៉េចដែរបងកាលពីតូចរហូតដល់អាឡូវហោសដូចជាផ្លាស់ប្តូរអីគេខ្លះហាស?

ខៈ
អូសព្វថ្ងៃកាលពីលើកមុនយើងផ្ទះស្បូវតែរាបអាសីតែអាឡូវនឹងបានស័ង្កសីហើយហើយមានឈើអីហើយថាជីវភាពយើងវាដូចថាគ្រាន់ជាងមុនហាសវាធូធារជាងមុនមិនដូចមុនទេរនាបអាសីផ្ទះប្រប់ស្បូវដើរទៅលោះតែអាឡូវដើរទៅមានក្តារមានអីទៅហើយប្រប់ដំបូលស័ង្កសីតែប៉ុណ្ណឹងអែង

កៈ ចុះបានសាងសងផ្ទះនឹងដោយខ្លួនអែងរឺមួយបានធ្វើផ្ទះនឹងទេ?

ខៈ
សាងសងខ្លួនអែងដើរយើងទៅស៊ីឈ្នួលគេទៅការឆ្នាំមកយើងបានលុយទៅហើយជួលគេយកមកធ្វើមក យើងទិញគ្រឿងឈើយកមកធ្វើទៅ

កៈ  ចុះបងមានជំនាញអីដែរបងចេះមកពីឪពុកម្តាយរបស់ទេ?

ខៈ
គ្មានជំនាញអីផងមានតែជំនាញដូចថាការយើងរកស៊ីតែប៉ុណ្ណឹងអែងថាយើងរកដើររកស៊ីស៊ី

ឈ្នួលគេតែប៉ុណ្ណឹងអែងដូចជាគ្មានជំនាញអីផងដូចថាវាចង់ធ្វើរឺចង់លក់ដូរអីដូចជាយើងគ្មានជំនាញអីផងយើងគ្មានលុយគ្មានកាក់ហាសនឹងអែងយើងចង់លក់ជីវភាពអីយើងមិនមានដូចគេហាស

ក៖

ចុះបងអាចប្រាប់ពីពេលដែរបងលំបាកក្នុងជីវិតរបស់បងបានទេដូចជាពេលណាហើយមានរឿងអីគេខ្លះដែរបងគិតថាបងពិបាកហាសណា?

ខ៖

ជូនកាលទៅពិបាកដែរជូនកាលទៅយើងថាយើងធូធារសព្វថ្ងៃហាសថាយើងធូធារមានផ្ទះមានអីនៅដូចថាវាគ្រាន់ជាងមុនហាស
ជូនកាលទៅថ្ងៃណាទៅដាច់ច្រក់ទៅរកតែបាយហូបមិនបានដែរនឹងហាសពេលខ្លះរកតែលុយ100រៀលជាបកាប៉ារមិនបានដែរមិនហាសព្រោះយើងអត់ធ្វើការ
ជូនកាលទៅយើងសំរាកការងារសំណង់ទៅដូចជាគេសំរាកអីចឹងទៅគេអស់ការងារទៅយើងដាច់លុយដាច់កាក់ដែរនឹងជីវភាពយើងពិបាកចិត្តតែប៉ុណ្ណឹងអែងពិបាកចិត្តតែអត់ធ្វើម៉េចអោយតែយើងបើយើងសប្បាយចិត្តអោយតែយើងមានអង្ករមានបាយម្ហូបយើងសប្បាយចិត្តហើយណាស់បើយើងមានតែផ្ទះហើយមិនទាន់មានដូចថាមិនមានអីធ្វើនឹងគេលុយក៏អត់ចាយបាយក៏អត់ហូបនៅតែគិតចឹងអែងការពិបាក នៅតែពិបាកចញ្ចឹងអែង

ក៖

ចុះពេលណាបើសិនជាបងជួបការលំបាកទាំងអស់នឹងហាសតើបងធ្វើម៉េចដើម្បីឈ្នះការលំបាកដែរបងបានជួបហាស

ខ៖

បងចង់ឈ្នះដែរនឹងហាសថាធ្វើម៉េចកុំអោយលំបាកដូចមុនចឹងហាសយើងត្រូវតស៊ូយើងត្រូវរលស្អីក៏យើងធ្វើដែរ ចាយើងមានការងារអីនៅកន្លែងក៏ដោយក៏យើងនៅតែធ្វើដែរ

ក៖

ហើយចុះពេលណាដែរបងគិតថាជាការពិសោធន៍ក្នុងជីវិតរបស់បងធ្វើអោយបងសប្បាយហាស?

ខ៖

មិនដឹងថាសប្បាយផងបើសប្បាយមានតែកូនរកលុយបានទៅកូនអោយលុយចាយទៅអីនឹ

ងមកអានឹងចេះតែសប្បាយអីបន្តិចមកអានឹងចេះតែសប្បាយហើយសប្បាយចិត្តទៅគិតបារម្ភពីកូនទៅរកស៊ីនៅស្រុកគេទៅ

កៈ
ចុះពេលដែរកាលបងនៅពីកូនក្មេងហាសបងធ្លាប់គិតថាបងចង់ធ្វើអីគេនៅពេលដែរបងធំឡើងទេ?

ខៈ
គ្មានថាគិតចង់ធ្វើអីផងម៉ែឪកំពុងតែអត់ចេះមិនដឹងថាចង់ធ្វើអីធ្វើម៉េចថាអោយតែបានលុយមកទុកទិញអង្ករអោយតែជីវភាពយើងគ្រប់គ្រាន់ទៅអាណ្ណឹងវាសប្បាយហើយ

កៈ
ចុះបើបងចង់ផ្តាំអីមួយទៅកូនៗនឹងចៅៗរបស់បងហាសតើបងនឹងប្រាប់អីគេខ្លះទៅកាន់ពួកគាត់ហាសបង?

ខៈ
ប្រាប់កូនៗនឹងអែងថាកូនកុំអោយអត់ឃ្លានអីធ្លាប់ឃើញម្តាយពិបាកពីដើមមកហើយអោយកូននឹងខំរកខំបានមានលុយមានកាក់កុំអោយជីវភាពយើងអត់ដូចមុនធ្លាប់យើងអត់ហើយហើយកូនហោដឹងគេធ្វើតាមយើងអត់យើងមិនដឹងទេយើងមិនដឹងដែរនឹងហាសព្រោះយើងចិត្ត
ចិត្តយើងផ្សេងចិត្តគេផ្សេងហើយចិត្តគេថាខំបើយើងមិនខំក៏យើងមិនដឹងធ្វើម៉េចធ្វើម៉េចគេព្រោះថាម្តាយបង្កើតយើងមកគេព្រោះម្តាយបានកើតមកតែពីតូចយើងប្រាប់គេអោយខំតែបើគេមិនរឺខំមិនដឹងធ្វម៉េចបើប្រាបើគេហើយបានតែនិយាយតាក់ទិចទៅប្រាប់ទៅកូនប្រដៅថាខំទៅកូនបើនិយាយប្រាប់កូនទៅកូនម៉ែអត់មានកូនខំរកខំអីចឹង
ដើម្បីទុកទល់ជីវភាពរបស់ខ្លួនយើងមានផ្តាំកូនទៅចញ្ចឹងអែង

កៈ
ចឹងបងសំរាប់ខ្ញុំខ្ញុំអរគុណបងច្រើនសំរាប់ពីការភាក្សាហើយនឹងផ្តល់ពីប្រវត្តិរបស់បងសំរាប់អោយពួកខ្ញុំចឹងហាសណាស់បងចាចឹងអរគុណច្រើនបង៕៕៕